ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៣៣...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរក្របខណ្ឌមន្ត្រីរាជការស៊ីវិល របស់ អតីតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា អតីតក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ក្រសួងអប់រំ យុវជន និងកីឡា និង ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការ ជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានការឯកភាពរបស់គណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ២០០៤

## សម្រេច

**មាត្រា១ :** ត្រូវបានផ្ទេរក្របខណ្ឌមន្ត្រីរាជការស៊ីវិលចំនួន ៥៥៦ នាក់ ( ដូចមានក្នុងឧបសម្ព័ន្ធជូនភ្ជាប់ ) របស់អគ្គនាយកដ្ឋានការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈព្រែកព្នៅ មជ្ឈមណ្ឌលអភិវឌ្ឍន៍មុខជំនាញកម្ពុជា-ថៃ (ពូនភ្នំ ) មន្ទីរសង្គមកិច្ចការងារ

www.pheakdeylaw.com

បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាខេត្ត-ក្រុង ដែលបំរើការងារវិស័យការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងផ្នែកការងាររដ្ឋបាល និងហិរញ្ញវត្ថុ នៃអតីតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា អោយមកបំរើ ការងារនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

**មាត្រា២ :** ត្រូវបានផ្ទេរក្របខណ្ឌមន្ត្រីរាជការស៊ីវិលចំនួន ៦៤ នាក់ ( ដូចមានក្នុងឧបសម្ព័ន្ធជូនភ្ជាប់ ) របស់នាយកដ្ឋានអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៃក្រសួងអប់រំ យុវជន និងកីឡា អោយមកបំរើការងារនៅក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ។

**មាត្រា៣ :** ត្រូវបានផ្ទេរក្របខណ្ឌមន្ត្រីរាជការស៊ីវិលចំនួន ៤០១ នាក់ (ដូចមានក្នុងឧបសម្ព័ន្ធជូនភ្ជាប់ ) របស់នាយកដ្ឋានសោធនអតីតយុទ្ធជន នាយកដ្ឋានអភិវឌ្ឍន៍អតីតយុទ្ធជន មជ្ឈមណ្ឌលព្យាបាលដោយចលនា និងមន្ទីរកិច្ចការនារី និងអតីតយុទ្ធជនខេត្ត-ក្រុង ដែលបំរើការងារវិស័យអតីតយុទ្ធជន នៃអតីតក្រសួងកិច្ចការនារី និងអតីតយុទ្ធ ជន អោយមកបំរើការងារនៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

**មាត្រា៤ :** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលរាជធានីភ្នំពេញ និងអភិបាលខេត្ត-ក្រុង មានការកិច្ចអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**ចំលងជូនៈ**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា៥

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com